# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ៖ ២០(ប)

-ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៣២១៨

-ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩

-សំណុំរឿងស៊ើបសួរលេខ៖ ៥៨៥០

-ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩

-សំណុំរឿងជំនុំជម្រះលេខ៖ ១២៧១

-ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ នៅសាលសវនាការទី២ វេលាម៉ោង១៤,៣០នាទី ដោយមានសមាសភាពដូចខាងក្រោម៖

**<u>ចៅក្រមជំនុំជម្រះ</u>**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៣២១៨ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ដែលមាន៖

ក/.<u>ជនជាប់ចោទ</u>៖

ឈ្មោះ [redacted] សំអឿន ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ អាសយដ្ឋានផ្ទះ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]សំអុល (រ) ម្តាយឈ្មោះ [redacted]ស៊ីយ៉ាន (រ) ប្រពន្ធឈ្មោះ [redacted] វិច្ឆរ៉ា មានកូន២នាក់ **ជានីតិជន**។

☑ ក្រៅឃុំ៖

☑ ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ៖ ដីកាលេខ៩៧៦៧(ង)ដពស ចុះថ្ងៃទី១៣/ធ្នូ/២០១៩

☐ ឃុំខ្លួនបណ្តោះអាសន្ន៖

ជាប់ចោទពីបទ៖ហិង្សាដោយចេតនា ប្រព្រឹត្តនៅផ្ទះលេខ១១៨៦ ផ្លូវលំ ក្រុមទី២ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨/មីនា/២០១៩ ផ្តន្ទាទោសតាមបញ្ញត្តមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ (ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០/វិច្ឆិកា/២០០៩)។

ខ/.<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>៖

ឈ្មោះ [redacted] *ម៉ារី* ហៅ *ស្រីតឿ* ភេទស្រី កើតឆ្នាំ១៩៩២ សញ្ជាតិខ្មែរ ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ អាសយដ្ឋានផ្ទះ[redacted]រាជធានីភ្នំពេញ។

<u>មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី</u>៖ មេធាវី [redacted]

**<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**



Scanned with CamScanner

កាលពីថ្ងៃទី២៨/មីនា/២០១៩ វេលាម៉ោង១៩,៥០នាទី នៅផ្ទះលេខ១១៨៦ ផ្លូវលំ ក្រុមទី២ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានករណីហិង្សាដោយចេតនាមួយបានកើតឡើង ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] សំអឿន ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ បានធ្វើសកម្មភាពវាយលើជនរងគ្រោះរងរបួស ដោយសាររឿងដាក់សម្រាមមុខផ្ទះ។

- បានឃើញរបាយការណ៍សំយោគលេខ០០៥/១៩ រ.ប.ក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៤៦០១ អ.យ.យ ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៩៧០ អ.យ.ត ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ១២២៨ (ង)ដ.ជ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

១/.ជនជាប់ចោទឈ្មោះ [redacted] សំអឿន ភេទប្រុស បានឆ្លើយថា៖ ចំពោះអង្គហេតុដែលតុលាការអានគឺមិនពិតនោះទេ។ ដើមហេតុដំបូងគឺរឿងការចោលសំរាម។ ខ្លួនប្រាប់ដើម្បីឲ្យស្អាតទាំងអស់គ្នា កុំឲ្យសំរាមចូលលូ ព្រោះកន្លែងនោះនៅជិតលូទឹក។ ខ្លួនបានស្នើរសុំឲ្យគាត់យកសំរាមនោះចេញ ដោយសារប្រពន្ធខ្លួនលក់ដូរនៅជិតនោះ តែគាត់មិនព្រមយកចេញ ហើយថែមទាំងជេរកូនខ្លួន និងដាក់បណ្ដាសារដល់កូនខ្លួន ហើយខ្លួនបានទៅសួរនាំគាត់ដោយខ្លួនឈរនៅក្បែរមាត់ទ្វារផ្ទះ ដោយខ្លួនគ្រាន់តែប្រាប់គាត់ថាយកសំរាមចេញ តែគាត់មិនព្រម។ ពេលនោះក៏បានឈ្លោះប្រកែកពាក្យសំដីគ្នា តែខ្លួនមិនបានប្រើអំពើហិង្សាលើគាត់នោះ ហើយម្ដាយឪពុករបស់ឈ្មោះ [redacted] ម៉ារី បានកាន់ដំបងស្មុះមករកវាយខ្លួន ខ្លួនមិនបានតដៃជាមួយគ្រួសាររបស់ឈ្មោះ [redacted] ម៉ារី ប្រសិនបើខ្លួនបានតបតមែន គឺម្ដាយឪពុករបស់ឈ្មោះ [redacted] ម៉ារី អាចនឹងធ្ងន់ធ្ងរ មានតែឈ្មោះ [redacted] ម៉ារី នោះទេដែលបានយកស្បែកជើងមកវាយខ្លួនថែមទៀត។ ចំពោះស្នាមជាំលើខ្លួនឈ្មោះ [redacted] ម៉ារី គឺខ្លួនមិនបានប្រព្រឹត្តនោះទេ ហើយការដាច់គន្លឹះទ្វារដែលមានក្នុងរូបថត ក៏ខ្លួនមិនបានទៅធ្វើឲ្យខូចខាតនោះដែរ គឺមានការខូចខាតស្រាប់។ ចំពោះការលើកឡើងរបស់ឈ្មោះ [redacted] ម៉ារី ថាខ្លួនបានទះកំភ្លៀងចំនួន២កំភ្លៀងនោះគឺមិនមែនជាការពិតនោះទេ។ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់ឈ្មោះ [redacted] ម៉ារី នោះទេ ហើយរូបថត និងការខូចខាត់ទ្វារផ្ទះនោះ គឺគ្រាន់ជាការរៀបចំរបស់ឈ្មោះ វិន ម៉ារី តែប៉ុណ្ណោះ ដើម្បីចោទប្រកាន់ខ្លួន។ ហើយពេលដែលឈ្លោះប្រកែកពាក្យសំដីគ្នាពិតជាមានមែន តែខ្លួនមិនបានចូលទៅក្នុងផ្ទះរបស់ឈ្មោះ [redacted] ម៉ារី នោះទេ ខ្លួនមិនបានធាក់ទ្វារចូលផ្ទះគេទេ។

២/.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ារី ភេទស្រី បានឆ្លើយថា៖ ចំពោះការលើកឡើងរបស់ឈ្មោះ [redacted] សំអឿន គឺមិនពិតនោះទេ។ នៅថ្ងៃកើតហេតុនោះ ម៉ាក់ខ្លួនកំពុងតែកើបកម្ទេចដី និងសំរាមក្បែរផ្ទះរបស់ឈ្មោះ [redacted] សំអឿន ហើយឈ្មោះ [redacted] សំអឿន បានចូលមកឈ្លោះប្រកែកគ្នាជាមួយខ្លួនដល់ក្នុងផ្ទះ ហើយឈ្មោះ [redacted] សំអឿន បានយកដំបងមកវាយខ្លួន និងបានទះកំភ្លៀងខ្លួនចំនួន២កំភ្លៀង។ ខ្លួនមិនបានយកស្បែកជើងវាយឈ្មោះ [redacted] សំអឿន នោះទេ ហើយម្ដាយខ្លួនមិនបានធ្វើទេ គឺមានតែឈ្មោះ [redacted] សំអឿន បានវាយខ្លួនចំនួន២កំភ្លៀង រួចក៏បានដើរចូលផ្ទះគាត់វិញ។ គ្រួសាររបស់ខ្លួន និងឈ្មោះ [redacted] សំអឿន គឺមិនស្និទ្ធស្នាលគ្នានោះទេ។

៣/.សាក្សីឈ្មោះ [redacted] ស៊ីបារ៉ូ ភេទស្រី បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានជិះម៉ូតូយកសត្វឆ្កែខ្លួនទៅចាក់ថ្នាំ។ ប៉ុន្តែគ្រូពេទ្យសត្វមិននៅផ្ទះ ក៏ទៅលេងផ្ទះរបស់ឈ្មោះ [redacted] ម៉ារី។ ពេលខ្លួនទៅដល់ក៏ឃើញមានការឈ្លោះប្រកែកគ្នា និងប្រតាយប្រតប់គ្នាយ៉ាងខ្លាំង ខ្លួនឃើញគាត់ប្រតាយប្រតប់គ្នា។ ខ្លួនបានឆ្លើយបំភ្លឺចំនួន២ដងរួចហើយ គឺនៅចំពោះមុខសមត្ថកិច្ច។ នៅថ្ងៃកើតហេតុនោះ ខ្លួនបានឃើញគេវាយឈ្មោះ [redacted] ម៉ារី ចំនួន២កំភ្លៀង។ កន្លងមកខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សំអឿន នោះទេ ចំពោះឈ្មោះ [redacted] ម៉ារី ខ្លួនស្គាល់ព្រោះជាមិត្តភក្តិគ្នា។

៤/.សាក្សីឈ្មោះ [redacted] សម័យ ភេទស្រី បានឆ្លើយថា៖ ផ្ទះខ្លួននៅតីឡូម៉ែត្រលេខ៦។ ខ្លួនស្គាល់គ្នាទាំងពីរ ព្រោះជាអ្នកជិតខាងគ្នា។ នៅវេលាម៉ោងប្រហែល៩យប់ ខ្លួនឃើញឈ្មោះ [redacted] សំអឿន ស្រែកជេរកមុខអ្នកយកសម្រាមដាក់ក្បែរផ្ទះគាត់។ គាត់ដើរជេរចុះឡើង។ ពេលឈ្លោះគ្នា ខ្លួនបានរុញកុំឱ្យឈ្លោះគ្នា ឈ្មោះ [redacted] សំអឿន បានចូលផ្ទះគេម្នាក់ឯង និងបានទះគេ២កំភ្លៀង ចំពោះអង្រែប្រពន្ធគាត់អ្នកកាន់អត់បានយកទៅវាយគេនោះទេ ហើយការទះ២កំភ្លៀងខ្លួនពិតជាបានឃើញពិតមែន។

៥/.សាក្សីឈ្មោះ [redacted] ចរិយា ភេទស្រី បានឆ្លើយថា៖ ផ្ទះខ្លួននៅជិតផ្ទះអ្នកទាំងពីរ។ នៅថ្ងៃកើតហេតុខ្លួនបានឃើញឈ្មោះ [redacted] សំអឿន ទះចំនួន២កំភ្លៀងលើឈ្មោះ [redacted] ម៉ារី ចំណែកតាយាយគាត់កាន់អង្រែ។

៦/.សាក្សីឈ្មោះ [redacted] សេរី ភេទស្រី បានឆ្លើយថា៖ ខ្លួនជួលផ្ទះរស់នៅជិតគ្នា។ នៅថ្ងៃកើត គឺខ្លួននៅជិតនោះដែរ ខ្លួនបានលឺសម្លេងតវ៉ាគ្នាពិតមែន។ ប៉ុន្តែខ្លួនមិនឃើញមានការវាយគ្នាទេ។ លឺតែសម្លេងតវ៉ាគ្នាប៉ុណ្ណោះ ព្រោះនៅថ្ងៃកើតហេតុខ្លួនមិនបានឃើញសកម្មភាពអ្វីនោះទេ។

៧/.សាក្សីឈ្មោះ [redacted] លីន ភេទប្រុស បានឆ្លើយថា៖ ខ្លួនជាឪពុករបស់ឈ្មោះ [redacted] ម៉ារី។ នៅថ្ងៃកើតឈ្មោះ [redacted] សំអឿន បានធាក់ទ្វារចូលមកក្នុងផ្ទះខ្លួន ហើយចូលទះកំភ្លៀងកូនខ្លួន។ ប្រពន្ធខ្លួនកំពុងឈឺ ដោយឈ្មោះ [redacted] សំអឿន មានកាន់ដំបងមកខ្លួនក៏រង ប្រពន្ធខ្លួនពិតជាបានកាន់អង្រែពិតមែន ប៉ុន្តែគាត់កាន់ដើម្បីការពារខ្លួនប៉ុណ្ណោះ។ នៅថ្ងៃនោះខ្លួនទប់ចិត្តណាស់មិនចង់ឱ្យមានរឿងនេះកើតឡើងទេ តែអំពើនេះនៅតែកើតឡើងនៅក្នុងផ្ទះខ្លួនទាល់តែបាន។ កូនស្រីខ្លួនមិនយកស្បែកជើងវាយជនបង្កនោះទេ។

៨/.សាក្សីឈ្មោះ [redacted] ណៃ ភេទស្រី អវត្តមាននាពេលសវនាការ ប៉ុន្តែនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយថា៖ នៅថ្ងៃទី២៦/មីនា/២០១៩ វេលាម៉ោង១៨,០០នាទី ខ្លួនបានលឺសម្លេងមនុស្សប្រុសស្រែកឡូឡា និងជេរប្រមាថរំពើរឿងសម្រាម ដែលខ្លួន និងប្តីខ្លួនឈ្មោះ [redacted] លីន យកទៅទុកនៅលើចិញ្ចើមផ្លូវក្បែររបងផ្ទះរបស់ឈ្មោះ [redacted] ឈួន។ ខ្លួនបានស្ទុះចេញពីក្នុងផ្ទះមកមើល ក៏ឃើញឈ្មោះប្រុស កំពុងតែស្រែកឡូឡា ប្រមាថមកលើក្រុមគ្រួសាររបស់ខ្លួន។ ពេលនោះខ្លួននិងប្តីរបស់ខ្លួនបាននិយាយប្រាប់ទៅឈ្មោះ ប្រុស ថា ខ្លួនបានហៅកម្មកររូសសម្រាម និងដីដែលច្រកស្បោង និងថង់នោះហើយ ប៉ុន្តែកម្មករនោះមិននៅផ្ទះ រង់ចាំបន្តិចសិនទៅ ប្តីខ្លួនបានទៅហៅកម្មករបន្ថែមទៀតហើយ។ ប៉ុន្តែឈ្មោះ ប្រុស នោះមិនព្រមស្តាប់តាមការនិយាយប្រាប់របស់ខ្លួនទេ ថែមទាំងស្រែកឡូឡាជេរប្រមាថមកលើក្រុមគ្រួសារខ្លួនរហូតដល់ប្រើអំពើហិង្សាវាយទ្វាររបងផ្ទះខ្លួន និងយកដុំថ្មគប់ទ្វាររបងខ្លួនរហូតទាល់តែរបើកគន្លឹះទ្វាររបង ពេលនោះក៏មានទំនាស់ពាក្យសម្តីជេរប្រមាថគ្នាទៅវិញទៅមក ហើយឈ្មោះ ប្រុស បានច្រានទ្វាររបងដែលវាយ និងគប់ឱ្យរបើកនោះចូលមកផ្ទះខ្លួន និងបង្កអំពើហិង្សា យកដុំបងវាយមកលើខ្លួន។ ពេលដែលខ្លួនកាន់អង្រែដើម្បីការពារខ្លួន ពីព្រោះឈ្មោះ ប្រុស បានចូលមកក្នុងផ្ទះរបស់ខ្លួនប្រើអំពើសាហាវ ជេរប្រមាថ យកដុំបងវាយមកលើខ្លួន តែបានប្តីរបស់ខ្លួនរងទាន់បណ្តាលឱ្យដំបងបាក់ជាពីរ និងជេរប្រមាថមកលើកូនស្រីខ្លួនឈ្មោះ [redacted] ម៉ារី ព្រមទាំងយកដុំវាយលើផ្ទៃមុខកូនស្រីខ្លួនចំនួន២ដៃ បណ្តាលឱ្យក្រហមផ្ទៃមុខ ពេលនោះកូនស្រីខ្លួនបានទូរស័ព្ទហៅសមត្ថកិច្ច បានចុះទៅដល់កន្លែងកើតហេតុ ហើយបានធ្វើការណែនាំ ឱ្យអនុវត្តតាមផ្លូវ

ច្បាប់។ ចំពោះរូបខ្លួន និងឈ្មោះ ប្រុស ព្រមទាំងក្រុមគ្រួសារបានចូលផ្ទះរៀងៗខ្លួន រីឯកូនស្រីរបស់ខ្លួនឈ្មោះ [redacted] ម៉ារី បាន មកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលគីឡូម៉ែត្រលេខ៦។

៩/.សាក្សីឈ្មោះ [redacted] សុខអូន ភេទប្រុស អវត្តមាននាពេលសវនាការ ប៉ុន្តែនៅចំពោះតំណាងអយ្យការបានឆ្លើយថា៖ នៅថ្ងៃមិនចាំខែមិនចាំ ឆ្នាំ២០១៩ វេលាម៉ោងប្រហែល៧ទៅ៨យប់ មិនស្គាល់ចំណុចកើតហេតុ ខ្លួនបានជិះម៉ូតូរ៉ឺម៉កឥវ៉ាន់ឱ្យគេនៅចំណុចនោះ។ ពេលមកដល់ ខ្លួនឃើញមនុស្សម្នាក់ឈ្មោះ ប្រុស ភេទប្រុស អាយុប្រហែល៤០ឆ្នាំ កំពុងឈ្លោះប្រកែកគ្នាជាមួយមនុស្សស្រីផ្សេងម្នាក់ទៀតមិនស្គាល់ឈ្មោះ កំពុងឈរនៅក្នុងផ្ទះ។ មួយសន្ទុះក្រោយមកក៏បានបើកទ្វារចេញមកក៏ម្នាក់ស្រីនោះបានទាញស្បែកជើងវាយក្បាលរបស់ឈ្មោះ ប្រុស នោះ រួចឈ្មោះ ប្រុស បានចាប់ជាប់ រួចក៏រុញនារីនោះចេញ បន្ទាប់មកពួកគេក៏បានដេរគ្នាទៅវិញទៅមក បន្ទាប់ពីដាក់ឥវ៉ាន់រួចខ្លួនក៏បានជិះម៉ូតូចេញទៅផ្ទះទៅ។

១០/.តាមអំណានរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ខណ្ឌឫស្សីកែវថា៖ ជនសង្ស័យឈ្មោះ [redacted] សំអឿន ភេទប្រុស អាយុ៣៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនា (វាយជនរងគ្រោះបណ្តាលឱ្យរងរបួសស្រាល) លើឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ២៧ឆ្នាំ កាលពីថ្ងៃទី២៦ ខែមីនា ខែ២០១៩ វេលាម៉ោង១៩,៥០នាទី នៅផ្ទះលេខ ១១៨៦ ផ្លូវលំ ក្រុមទី២ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រាកដមែន។

## <u>សេចក្តីសន្និដ្ឋានការពាររបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី</u>

មេធាវី [redacted] ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖

-ក្រោយពីបានស្តាប់ការពិភាក្សាសួរដេញដោយក្នុងអង្គសវនាការ

-ក្រោយពីបានស្តាប់ការឆ្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ការឆ្លើយដោះសាររបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ការបភ្លឺរបស់សាក្សី

-ក្រោយពីបានពិនិត្យមើលសំណុំរឿងចប់សព្វគ្រប់ ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] សំអឿន ហៅ ប្រុស ពិតជាបានប្រព្រឹត្តិអំពើហឹង្សាមកលើកូនក្តីរបស់ខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ារី ហៅ (ភឿ) ដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៦/មីនា/២០១៩ ពិតប្រាកដមែន ។

### I-អង្គហេតុ

កាលពីថ្ងៃទី២៦/មីនា/២០១៩ ជនជាប់ចោទឈ្មោះ [redacted] សំអឿន ហៅ (ប្រុស) បានមកជេរប្រមាថមកលើកូនក្តីខ្ញុំបាទ និងក្រុមគ្រួសារ។ បន្ទាប់មកជនជាប់ចោទបានធាក់ទ្វាររបងផ្ទះបណ្តាលឱ្យរបើក រួចយកដុំថ្មមកគប់សំដៅទៅម្តាយរបស់កូនក្តីខ្ញុំបាទឈ្មោះ [redacted] ណៃ ប៉ុន្តែមិនត្រូវក៏ត្រូវចំជើងកូនក្តីខ្លួន។ បន្ទាប់មកជនជាប់ចោទក៏ដើរចូលទៅក្នុងផ្ទះរបស់កូនក្តីខ្លួន ហើយវាយចំមុខចំនួន២ដៃទៀត និងយកដំបងឈើប្រវែងប្រហែលកន្លះម៉ែត្រមកវាយលើកូនក្តីខ្លួន តែមិនត្រូវដោយសារឪពុកឈ្មោះ [redacted] លីន) យកដៃទៅរងដំបងនោះជំនួស ត្រូវដៃបាក់ដំបងជា២កំណាត់បណ្តាលឱ្យហើមដៃ។ ច្បាស់ជាងនេះទៅទៀតសាក្សី៣នាក់ដែលបានឃើញហេតុការណ៍ផ្ទាល់ និងភ្នែកមានឈ្មោះ [redacted] សម័យ ឈ្មោះ [redacted] ចរិយា ឈ្មោះ [redacted] ស៊ីប៉ាវ៉ូ បានបំភ្លឺនៅក្នុងកំណត់ហេតុកាលពីថ្ងៃទី៣/មេសា/២០១៩ នៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់គីឡូម៉ែត្រលេខ៦ ពីសកម្មភាពរបស់ជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើសហិង្សា ដោយភ្ជាប់ជាមួយអាវុធមានដុំថ្ម ដំបងឈើ វាយមកលើជនរងគ្រោះឈ្មោះ [redacted] ម៉ារី មានភាពស៊ីសង្វាក់គ្នាជាមួយភស្តុតាង និងរបាយការណ៍សំយោគរបស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ចុះថ្ងៃទី២២/ឧសភា/២០១៩ ផងដែរ។ ដោយឡែកសាក្សីឈ្មោះ [redacted] សុខអូន និងឈ្មោះ [redacted]



Scanned with CamScanner

សេរី ដែលបានបំភ្លឺនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃ២២/កក្កដា/២០១៩ បានបំភ្លឺនូវហេតុការណ៍នៅថ្ងៃខែឆ្នាំ ម៉ោងដូចគ្នាតែផ្តល់នូវចម្លើយខុសគ្នា។ ចំណុចនេះសបញ្ជាក់ឲ្យឃើញថា សាក្សីទាំង២ខាងលើ គឺមិនស្ថិតក្នុងហេតុការណ៍ ហើយក៏មិនបានឃើញហេតុការណ៍ នោះច្បាស់ដែរ ។

## II-<u>អង្គច្បាប់</u>

យោងតាមភស្តុតាង និងសាក្សី ជនជាប់ចោទពិតជាបានប្រព្រឹត្តិហឹង្សាមកលើជនរងគ្រោះ ដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៦/មីនា/២០១៩ ពិតប្រាកដមែន។ ប៉ុន្តែដោយជនជាប់ចោទបានធ្វើសកម្មភាពភ្ជាប់ជាមួយអាវុធដុំថ្ម និងដំបងឈើវាយមកលើជនរងគ្រោះ។ ដូចនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ សូមឲ្យតុលាមេត្តាពិចារណាដោយប្តូរបទចោទហឹង្សាដោយចេតនា តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ មកបទចោទហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

## III-<u>សំណូមពរ</u>

ដោយផ្អែកតាមអង្គហេតុ និងអង្គច្បាប់ដូចបានជម្រាបជូនខាងលើ ខ្លួនស្នើសុំ៖

-សុំឲ្យតុលាការផ្តន្ទាទោសតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ និងចេញដីការចាប់ខ្លួនជនជាប់ចោទ។

-សុំទាមទារសំណងជំងឺចិត្ត និងថ្លៃព្យាបាលលើការចំណាយផ្សេងៗសរុបចំនួន១០,000 (មួយម៉ឺនដុល្លារ)។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

-<u>តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា</u>៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមកឃើញថាជនជាប់ចោទឈ្មោះ [redacted] សំអឿន ភេទប្រុស បានឆ្លើយបដិសេធចំពោះការប្រព្រឹត្តរបស់ខ្លួនថាខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ប៉ុន្តែមិនមានភស្តុតាងណាអាចដោះបន្ទុកបានឡើង ដោយឡែកជនរងគ្រោះពុំបានប្រើដុំបងនោះទេ ហើយសាក្សី២នាក់ទៀតពុំបានឃើញវាយគ្នាទេ សុំឲ្យចៅក្រមជំនុំជម្រះពិចារណាចំពោះសាក្សី២នាក់ដែលពុំបានឃើញហេតុការណ៍។ ហេតុដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ៩៧០ អ.យ.ត ចុះថ្ងៃទី២/មីនា/២០២០ ទុកជាបានការដដែល និងសុំឲ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

## <u>សំដីចុងក្រោយរបស់ជនជាប់ចោទ</u>

-ជនជាប់ចោទឈ្មោះ [redacted] សំអឿន ភេទប្រុស បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សូមតុលាការលើកលែងការចោទប្រកាន់។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ ម៉ៅ សំអឿន ភេទប្រុស
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន ភេទប្រុស
- ក្រោយពីបានពិនិត្យឯកសារ ភស្តុតាងនានា
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>សំអាងហេតុ</u>



Scanned with CamScanner

១/.កាលពីថ្ងៃទី២៨/មីនា/២០១៩ ឈ្មោះ [redacted] សំអៀន ភេទប្រុស អាយុ៣៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនាលើឈ្មោះ [redacted] ម៉ារី ភេទស្រី នៅផ្ទះលេខ១១៨៦ ផ្លូវលំ ក្រុមទី២ ភូមិក្រោលគោ សង្កាត់គីឡូលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រាកដមែន។

២/.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស នាពេលសវនាការថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ចម្លើយនេះមិនមានភស្តុតាងណាមកដោះបន្ទុកដើម្បីឱ្យតុលាការមានជំនឿសិប់ឡើយ។ គប្បីតុលាការពិនិត្យ ពិចារណា និងសម្រេចនៅក្នុងសេចក្តីសម្រេច។

៣/.ចម្លើយជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស ចម្លើយជនរងគ្រោះ ចម្លើយសាក្សី និងឯកសារនៅក្នុងសំណុំរឿងជាភស្តុតាងមានភាពស៊ីសង្វាក់បង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនា លើជនរងគ្រោះឈ្មោះ [redacted] ម៉ារី ភេទស្រី កាលពីថ្ងៃទី២៨/មីនា/២០១៩ នៅផ្ទះលេខ១១៨៦ ផ្លូវលំ ក្រុមទី២ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រាកដមែន។

៤/.ជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស អាយុ៣៨ឆ្នាំ ក្នុងពេលប្រព្រឹត្តបទល្មើស និងក្រោយពេលប្រព្រឹត្តបទល្មើស ជាសមត្ថជន មានសមត្ថភាព លទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

៥/.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស បង្ហាញឱ្យឃើញថាប្រព្រឹត្តធ្វើឱ្យខូចរបៀបរៀបរយសាធារណៈ សណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជន និងនីត្យានុកូលភាពសង្គម បំពានមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

៦/.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស ពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅផ្ទះលេខ១១៨៦ ផ្លូវលំ ក្រុមទី២ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨/មីនា/២០១៩ ផ្តន្ទាទោសតាមបញ្ញត្តមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

៧/.ជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស ក្រោយពីបានប្រព្រឹត្តបទល្មើស មិនសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួននាពេលសវនាការ មិនមានស្មារតីភ្ញាក់រលឹក កែប្រែខ្លួនដើម្បីវិលចូលក្នុងសង្គមជាតិ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចនៅក្នុងសេចក្តីសម្រេច។

៨/.តំណាងអយ្យការពេលសវនាការធ្វើការសន្និដ្ឋានប្តឹងសុំថា សុំទៅក្រុមជំនុំជំរះផ្តន្ទាទោសជនជាប់ចោទពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅផ្ទះលេខ១១៨៦ ផ្លូវលំ ក្រុមទី២ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨/មីនា/២០១៩ តាមបញ្ញត្តមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីតុលាការពិនិត្យ ពិចារណា និងសម្រេចក្នុងសម្រេចសេចក្តី។

៩/.ជនជាប់ចោទឈ្មោះ [redacted] សំអៀន ភេទប្រុស បាននិយាយសំដីចុងក្រោយសូមតុលាការលើកលែងការចោទប្រកាន់។ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

## ហេតុដូច្នេះសម្រេច

១/.ផ្តន្ទាទោសឈ្មោះ [redacted] សំអៀន ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១(មួយ)ឆ្នាំ ពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅផ្ទះលេខ១១៨៦ ផ្លូវលំ ក្រុមទី២ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨/មីនា/២០១៩ តាមបញ្ញត្តមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

២/.បង្គាប់ឲ្យឈ្មោះ [redacted] *សំអឿន* ភេទប្រុស អាយុ៣៨ឆ្នាំ សងសំណងរដ្ឋប្បវេណីចំនួន៤,000,000 (បួនលាន)រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] *ម៉ារី* ហៅ *តៀ* ភេទស្រី។

៣/.សាលក្រមជំនុំជម្រះសាធារណៈ នៅថ្ងៃទី១៧/ធ្នូ/២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំអឿន ភេទប្រុស និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ារី ភេទស្រី និងប្រកាសជាសាធារណៈនៅថ្ងៃទី៥/មករា/២០២១។

៤/.គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់។

| | |
|---|---|
| **ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

| | |
|---|---|
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| **ចៅក្រមជំនុំជម្រះ** | ថ្ងៃអង្គារ ៧រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤ |
| | ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៥ ខែមករា ឆ្នាំ២០២១ |
| | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |